# I - ទីស្តីការគណៈរដ្ឋមន្ត្រី

## ១ - អនុក្រឹត្យ

រាជធានីភ្នំពេញ ,ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ : ១៥ អនក្រ.បក**

**ស្តីពីការបង្កើតទិវាបរិស្ថានជាតិ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងបរិស្ថាន

**សំរេច**

**ប្រការ ១** : កំណត់យកថ្ងៃ ០៥ ខែ មិថុនា រៀងរាល់ឆ្នាំ ដែលជាទិវាបរិស្ថានពិភពលោកធ្វើជាទិវាបរិស្ថានជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២** : ទិវាបរិស្ថានជាតិ « ០៥ មិថុនា » គ្រប់ក្រសួង ស្ថាប័នរដ្ឋ គ្រប់ខេត្ត-ក្រុង ក្រុមហ៊ុនឯកជន សមាគមនានា ត្រូវបំផុសអប់រំជូនមន្ត្រីរាជការ កងទ័ពគ្រប់ប្រភេទ សិស្ស និស្សិត ព្រះសង្ឃ ប្រជារាស្ត្រ អំពីនយោបាយបរិស្ថានជាតិ គោលការណ៍យុទ្ធសាស្ត្រច្បាប់ បទបញ្ញត្តិនានា ស្តីអំពីការគ្រប់គ្រងធនធានធម្មជាតិ និងកិច្ចការពារបរិស្ថាន ។

**ប្រការ ៣** : ទិវាបរិស្ថានជាតិ « ០៥ មិថុនា » គ្រប់ក្រសួង ស្ថាប័នរដ្ឋ គ្រប់ខេត្ត-ក្រុង ក្រុមហ៊ុនឯកជន សមាគមនានា ត្រូវបំផុសចលនាឱ្យមន្ត្រីរាជការ កងទ័ពគ្រប់ប្រភេទ សិស្ស និស្សិត ព្រះសង្ឃប្រជារាស្ត្រ ដាំដើមឈើ និងចលនាការពារព្រៃឈើក្នុង បុព្វហេតុធ្វើអោយព្រះរាជាណាចក្រកម្ពុជាបៃតងជានិច្ចនិរន្តរ៍ ។

**ប្រការ ៤** : ទិវាបរិស្ថានជាតិ « ០៥ មិថុនា » ក្រសួងបរិស្ថានត្រូវធ្វើរបាយការណ៍ជាសាធារណៈចំពោះមុខរាជរដ្ឋាភិបាល ពីការបូកសរុបលទ្ធផលក្នុងកិច្ចការពារបរិស្ថាន ។

**ប្រការ ៥** : ក្រសួងបរិស្ថានត្រូវសហការជាមួយគណៈកម្មាធិការបុណ្យជាតិ ក្រសួង ស្ថាប័នរដ្ឋ គ្រប់ខេត្ត-ក្រុង អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ក្រុមហ៊ុនឯកជន សមាគមនានា ដើម្បីចាត់ចែងរៀបចំទិវាបរិស្ថានជាតិ «០៥ មិថុនា» របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៦** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មាធិការបុណ្យជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា
**នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ : ១៦ អនក្រ.បក**

**ស្តីពីការបញ្ចូលកងពលធំថ្មើរជើងលេខ ២ និង**

**កងពលធំថ្មើរជើងលេខ ១៤ ជាកងពលធំតែមួយ**